# កិច្ចប្រជុំរៀបចំផែនការថ្នាក់តំបន់របស់សហព័ន្ធអន្តរជាតិដើម្បីកម្មករការងារតាមផ្ទះ ស្តីពី ការមិនសណ្តោសប្រណីដល់អំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់កម្មករការងារតាមផ្ទះ នៅក្នុងពិភពការងារ ថ្ងៃទី២៧-២៩ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារ ប៉ាឡាហ្សូ, ទីក្រុងបាងកក ប្រទេសថៃ

# សេចក្តីថ្លែងការណ៍សម្រាប់ទិវាការងារអន្តរជាតិ

យើងទាំងអស់គ្នា ជាអ្នកចូលរួម **កិច្ចប្រជុំរៀបចំផែនការថ្នាក់តំបន់របស់សហព័ន្ធអន្តរជាតិដើម្បីកម្មករការងារតាមផ្ទះ** ក្រោមប្រធានបទ **ការមិនសណ្តោសប្រណីដល់អំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់កម្មករការងារតាមផ្ទះ នៅក្នុងពិភពការងារ** ដែលបានរៀបចំឡើងកាលពីថ្ងៃទី២៧ ដល់ ២៩ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារ ប៉ាឡាហ្សូ, ទីក្រុងបាងកក ប្រទេសថៃ ដោយមានការចូលរួមរបស់តំណាងកម្មករការងារតាមផ្ទះ មកពីប្រទេសបង់ក្លាដេស កម្ពុជា ហុងកុង ឥណ្ឌូណេស៊ី ឥណ្ឌា កូរ៉េខាងត្បូង ណេប៉ាល់ ម៉ាឡេស៊ី ហ្វីលីពីន និងថៃ។ ក្នុងឱកាសទិវាការងារអន្តរជាតិ យើងខ្ញុំ សូមអំពាវនាវដល់ រដ្ឋាភិបាលក្នុងទ្វីបអាស៊ី ឲ្យធ្វើការឆ្លើយតបចំពោះស្ថានភាពនៃអំពើហិង្សាយេនឌ័រ ដែលកម្មករការងារតាមផ្ទះ បានប្រឈម និងសូមឲ្យរដ្ឋាភិបាលចាត់វិធានការ។

ក្នុងកម្រិតសាកលលោក ស្ត្រីម្នាក់ក្នុងចំណោមបីនាក់ បានទទួលរងការបៀតបៀនផ្លូវកាយនិង/ឬផ្លូវភេទ ក្នុងទម្រង់ណាមួយ នៅក្នុងជីវិតរបស់ខ្លួន (តាមការប៉ាន់ប្រមាណរបស់អង្គការសុខភាពពិភពលោក)។ កម្មករការងារតាមផ្ទះ មានភាពងាយរងគ្រោះបំផុត ដោយសារតែពួកគេជាស្ត្រីភាគច្រើនបំផុតដែលចេញមកពីសហគមន៍ខ្វះខាតជីវភាពខ្លាំង ដែលកំពុងធ្វើការក្នុងគ្រួសាររបស់និយោជក។ យើងបានឮរឿងរ៉ាវនៃការបំពាននេះច្រើនគ្រប់គ្រាន់ហើយ។ អាដេលីណា សៅ ដែលកម្មករចំណាកស្រុកធ្វើការតាមផ្ទះជនជាតិឥណ្ឌូណេស៊ី បានស្លាប់ ដោយសារការធ្វើទារុណកម្មធ្ងន់ធ្ងរពីនិយោជករបស់នាងក្នុងប្រទេសម៉ាឡេស៊ី។ សាប៊ីណាខាទន់ កម្មករការងារតាមផ្ទះជាអនីតិជនម្នាក់ នៅក្នុងប្រទេសឥណ្ឌា ត្រូវបានកូនរបស់និយោជកនិងអ្នកបើកបររថយន្តរបស់គ្រួសារនោះ រំលោភសេពសន្ថវៈ និងបានស្លាប់។ ជនល្មើសនៃករណីទាំងពីរ នៅតែកំពុងរស់នៅដោយសេរីនៅឡើយ!

អាដេលីណា និង សាប៊ីណា គ្រាន់តែជាករណីមួយចំនួនក្នុងចំណោមករណីជាច្រើនទៀត ដែលទទួលរងអំពើហិង្សានិងការបៀតបៀន។ ការស្ទង់មតិរបស់**សហព័ន្ធអន្តរជាតិដើម្បីកម្មករការងារតាមផ្ទះ**ស្តីពីអំពើហិង្សាយេនឌ័រ ក្នុងចំណោមសមាជិករបស់យើងក្នុងទ្វីបអាស៊ី ក្នុងឆ្នាំ២០១៨ បានបង្ហាញថា កម្មករការងារតាមផ្ទះ ប្រឈមនឹងហានិភ័យនៃអំពើហិង្សានិងការបៀតបៀន នៅក្នុងគ្រួសារដែលពួកគេកំពុងធ្វើការ នៅក្នុងប្រភេទនិងកម្រិតផ្សេងៗគ្នា។ ការបំពានសាមញ្ញៗបំផុតដែលកម្មករការងារតាមផ្ទះប្រឈមមុខ គឺការបំពានផ្នែកហិរញ្ញវត្ថុ/សេដ្ឋកិច្ច រួមមាន ប្រាក់កម្រៃទាបនិងកម្រៃជើងសារខ្ពស់ពីទីភ្នាក់ងារផ្តល់ការងារ ជាពិសេសសម្រាប់កម្មករចំណាកស្រុក។ ទម្រង់នៃការបំពានផ្សេងទៀត មានអំពើហិង្សានិងការបៀតបៀនផ្លូវកាយ ផ្លូវចិត្ត ពាក្យសម្តី និងផ្លូវភេទ។ ការបំពានទាំងនេះ នាំមកនូវផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរចំពោះកម្មករការងារតាមផ្ទះ និងជីវិតគ្រួសាររបស់ពួកគេ។ ក៏ប៉ុន្តែ ជារឿយៗ ពួកគេមានការភ័យខ្លាចក្នុងការរាយការណ៍ អំពីការបៀតបៀននិងការបំពានផ្លូវភេទទាំងនេះ។

បន្ថែមពីលើនេះ អំពើហិង្សាក្នុងគ្រួសារ នាំមកនូវផលប៉ះពាល់រំខានទៅលើជីវិតនិងការងាររបស់កម្មករនានា។ ជារឿយៗ ស្ថានភាពអំពើហិង្សាក្នុងគ្រួសារ បន្សល់ទុកឲ្យកម្មករការងារតាមផ្ទះ នូវបន្ទុកហិរញ្ញវត្ថុនិងបន្ទុកផ្លូវចិត្តបន្ថែមទៀត ប៉ុន្តែ ពួកគេមិនទាន់ទទួលបានការគាំទ្រគ្រប់គ្រាន់នៅឡើយទេ។

អំពើហិង្សាដែលវិស័យកម្មករការងារតាមផ្ទះ ប្រឈមមុខ នៅតែបន្តកើតឡើងយ៉ាងច្រើន និងក្លាយទៅជាភាពសាមញ្ញ ដោយសារតែការងារតាមផ្ទះ មិនត្រូវបានទទួលស្គាល់និងត្រូវបានគេឲ្យតម្លៃទាប ថ្វីត្បិតតែពួកគេបានរួមចំណែកយ៉ាងច្រើន ដល់សេដ្ឋកិច្ច និងផលិតកម្មសង្គមក៏ដោយ។ ពួកគេទទួលរងការរើសអើងនិងត្រូវបានគេផាត់ចេញជាប្រព័ន្ធ ពី

សិទ្ធិការងារជាមូលដ្ឋាន។ ពួកគេប្រឈមនឹងការរើសអើងច្រើនស្រទាប់ ដោយសារមូលហេតុ យេនឌ័រ ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម សាសនា ដើមកំណើត ជាតិពន្ធុ អត្តសញ្ញាណយេនឌ័រ និន្នាការផ្លូវភេទ សមត្ថភាព ឋានៈគ្រួសារ អាយុ និងវណ្ណៈសង្គម។

កម្មករការងារតាមផ្ទះ ត្រូវការការការពារបន្ទាន់ប្រឆាំងនឹងរាល់ទម្រង់នៃការបំពាន ការបៀតបៀន និងអំពើហិង្សា (ដូចមានចែងនៅក្នុងអនុសញ្ញាអង្គការអន្តរជាតិខាងការងារ C១៨៩ មាត្រា ៣, ៤, ៥ និង ១១) ដោយរួមទាំង អំពើហិង្សាយេនឌ័រ។ យើងជឿជាក់ថា សមភាពយេនឌ័រនិងយុត្តិធម៌យេនឌ័រ និង ការមិនទុកនរណាម្នាក់ចោលពីការងារសមរម្យ គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍និងនិរន្តរភាពសង្គម។

អាស្រ័យហេតុដូច្នេះហើយ យើងខ្ញុំ សូមអំពាវនាវដល់រដ្ឋាភិបាលក្នុងទ្វីបអាស៊ីៈ

1. គាំទ្រដល់អនុសញ្ញាអន្តរជាតិរបស់អង្គការអន្តរជាតិខាងការងារ ស្តីពី "**បញ្ចប់អំពើហិង្សានិងការបៀតបៀន នៅក្នុងពិភពការងារ**" ដែលមានបន្ថែមដោយអនុសាសន៍ នៅក្នុងសន្និសីទរបស់អង្គការអន្តរជាតិខាងការងារ ក្នុងខែមិថុនាខាងមុខនេះ។
2. ផ្តល់សច្ចាប័នអនុសញ្ញាអង្គការអន្តរជាតិខាងការងារ ILO C189 ស្តីពី **ការងារសមរម្យសម្រាប់កម្មករការងារតាមផ្ទះ**។ ទទួលស្គាល់កម្មករការងារតាមផ្ទះ ជាកម្មករ នៅក្នុងច្បាប់និងគោលនយោបាយទាំងអស់។ ការដាក់បញ្ចូលកម្មករការងារតាមផ្ទះនៅក្នុងច្បាប់ស្តីពីការបៀតបៀនផ្លូវភេទទៅលើស្ត្រីនៅកន្លែងការងារ នៅក្នុងប្រទេសឥណ្ឌា គឺជាឧទាហរណ៍មួយនៃការដាក់បញ្ចូលនេះ។
3. លើកកម្ពស់និងសម្រេចឲ្យបានតាមគោលការណ៍និងអនុសញ្ញាស្តីពីសិទ្ធិមនុស្សទាំងអស់ ព្រមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) គោលដៅលេខ៥ ស្តីពី សមភាពយេនឌ័រ និង គោលដៅលេខ៨ ស្តីពីការងារសមរម្យ។
4. បង្កើតច្បាប់និងគោលនយោបាយ ដើម្បីការពារជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។
5. ធានាឲ្យមានការពង្រឹងការអនុវត្តនិងតាមដានច្បាប់និងគោលនយោបាយពាក់ព័ន្ធ។

* * * * * * * * *

សហព័ន្ធអន្តរជាតិដើម្បីអ្នកធ្វើការងារតាមផ្ទះ (IDWF)
សហជីពជាតិកម្មករការងារតាមផ្ទះ (NDWWU), ប្រទេសបង់ក្លាដេស
បណ្តាញកម្មករការងារតាមផ្ទះកម្ពុជា (CDWN), ប្រទេសកម្ពុជា
សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW), ប្រទេសកម្ពុជា
សហព័ន្ធសហជីពកម្មករការងារតាមផ្ទះនៅអាស៊ី ប្រចាំទីក្រុងហុងកុង (FADWU), ហុងកុង
បណ្តាញតស៊ូមតិថ្នាក់ជាតិដើម្បីកម្មករការងារតាមផ្ទះ (Jala PRT), ប្រទេសឥណ្ឌូណេស៊ី
សហព័ន្ធជាតិកម្មករការងារតាមផ្ទះ (NDWF), ប្រទេសឥណ្ឌា
ចលនាជាតិកម្មករការងារតាមផ្ទះ (NDWM), ប្រទេសឥណ្ឌា
សមាគមស្ត្រីមានមុខរបរផ្ទាល់ខ្លួន (SEWA), ប្រទេសឥណ្ឌា
សហករណ៍ជាតិអ្នកគ្រប់គ្រងផ្ទះ (NHMC), ប្រទេសកូរ៉េខាងត្បូង
សហជីពណេប៉ាល់កម្មករការងារតាមផ្ទះ (HUN), ប្រទេសណេប៉ាល់
សមាគមកម្មករនិយោជិតហ្វីលីពីនក្រៅប្រទេស (AMMPO), ប្រទេសម៉ាឡេស៊ី
អង្គការកម្មករការងារតាមផ្ទះរួបរួមគ្នាប្រទេសហ្វីលីពីន (UNITED), ប្រទេសហ្វីលីពីន
បណ្តាញកម្មករការងារតាមផ្ទះប្រទេសថៃ (NDWT), ប្រទេសថៃ